## តើការត្រួតពិនិត្យ ជាអ្វី?

ទារកទាំងអស់គឺត្រូវបានធ្វើតេស្តរកសញ្ញាបញ្ហាសុខភាពខ្លះ ដែលអាចមាន ។ ការធ្វើតេស្តទាំងនេះគេហៅថា Screening (ការត្រួតពិនិត្យ) ។

## តើការត្រួតពិនិត្យសោតវិញ្ញាណកូនទើបកើត ជាអ្វី?

ទារករបស់អ្នកនឹងត្រូវធ្វើតេស្តនៅឯមន្ទីរពេទ្យ ដើម្បីពិនិត្យមើលបញ្ហាសោតវិញ្ញាណ (អាការនៃការស្តាប់ឮ) របស់វា ។

## តើការត្រួតពិនិត្យសោតវិញ្ញាណ ត្រូវបានធ្វើដោយរបៀបណា?

ម៉ាស៊ីនពិសេសម្យ៉ាងនឹងបង្ហាញឲ្យដឹង បើសិនជាទារករបស់អ្នក តបឆ្លើយចំពោះសំឡេង ។ ការធ្វើតេស្តនេះគឺងាយស្រួល ហើយក៏មិនបណ្តាលឲ្យឈឺចាប់ទេ ។ អ្នកនឹងទទួលលទ្ធផលពីការធ្វើតេស្ត មុនពេលអ្នកចេញពីមន្ទីរពេទ្យ ។

## តើហេតុអ្វីបានជាវាសំខាន់ ដើម្បីឲ្យគេត្រួតពិនិត្យសោតវិញ្ញាណទារករបស់អ្នក?

បើសិនជាទារករបស់អ្នកមានខូចសោតវិញ្ញាណ នោះវាគឺជាសារៈសំខាន់ ដើម្បីពិនិត្យឲ្យដឹងពីដើមដំបូង និងទទួលការថែទាំ ដើម្បីជួយក្នុងការរៀនសូត្រ និងភាសា ។

---

*ទារកប្រហែល 3-4 នាក់ ក្នុងបណ្តាទារក 1,000 នាក់ នឹងមានការខូចសោតវិញ្ញាណបែបខ្លះ នៅពេលកើត ។*

---



*ការធ្វើតេស្តជាបន្តបន្ទាប់មានសារៈសំខាន់ណាស់ ។ បើសិនទារករបស់អ្នកមខូចសោតវិញ្ញាណ អ្នកនឹងចង់រកឲ្យដឹង ពីដើមដំបូង ។*

## តើវាមានន័យយ៉ាងណា បើសិនការត្រួតពិនិត្យសោតវិញ្ញាណទារករបស់អ្នកមិនធម្មតា?

បើសិនការត្រួតពិនិត្យសោតវិញ្ញាណទារករបស់អ្នកមិនធម្មតា គឺមានន័យថាទារករបស់អ្នក ត្រូវការធ្វើតេស្តសោតវិញ្ញាណថែមទៀត ។ ការធ្វើតេស្តទាំងនេះនឹងផ្តល់ព័ត៌មានឲ្យអ្នកថែមទៀត អំពីការស្តាប់ឮនៃទារករបស់អ្នក ។

## តើអ្នកទៅធ្វើតេស្តសោតវិញ្ញាណ ជាបន្តបន្ទាប់ នៅទីណា?

មន្ទីរពេទ្យនឹងរៀបចំការណាត់ពេលជួប សំរាប់ទារករបស់អ្នកទៅ ធ្វើតេស្តសោតវិញ្ញាណជាបន្តបន្ទាប់ ។ បើមន្ទីរពេទ្យមិនប្រាប់អ្នកអំពីការណាត់ពេលជួបអ្នកទេ អ្នកអាចទូរស័ព្ទទៅកម្មវិធីជាសាកល ត្រួតពិនិត្យសោតវិញ្ញាណកូនទើបកើត (Universal Newborn Hearing Screening Program) តាមលេខ 800-882-1435 ដើម្បីរកទីកន្លែងដែលអ្នកអាចទៅធ្វើតេស្តជាបន្តបន្ទាប់ ។

## តើខ្ញុំគួរតែធ្វើអ្វីខ្លះ បើទារករបស់ខ្ញុំ បានទទួលការវិនិច្ឆ័យរោគ ថាមានខូចសោតវិញ្ញាណ?

គ្រួសារត្រូវធ្វើការជាមួយនឹងគ្រូពេទ្យទារករបស់គេ ជាមួយនឹងអ្នកជំនាញខាងសំឡេង ព្រមទាំងជាមួយនឹងអ្នកផ្តល់ការថែទាំសុខភាពផ្សេងៗទៀត ដើម្បីសំរេចអំពីការបំរើអ្វីខ្លះ ដែលសំខាន់សំរាប់កូនរបស់គេ ។ ជារឿយៗ គ្រួសាររមែងតែប្រើកម្មវិធីអន្តរា គមន៍ពេលវ័យដំបូង (Early Intervention Program) នៅក្នុងសហគមន៍របស់គេ ដែលផ្តល់ការបំរើដោយអាស្រ័យទៅលើសេចក្តីត្រូវការរបស់ក្មេង និងគ្រួសារ ។

Universal
Newborn Hearing
Screening Program

*ទារកជាច្រើនដែលខូចសោតវិញ្ញាណ នឹងភ្ញាក់ៗដោយការឮសំឡេងខ្លាំងៗ ។ បើទារករបស់អ្នកមានខូចសោតវិញ្ញាណ មានតែការធ្វើតេស្តសោតវិញ្ញាណប៉ុណ្ណោះ ដែលអាចប្រាប់បាន ។*

ទារកមួយចំនួនអាចនឹងត្រូវការធ្វើតេស្តសោតវិញ្ញាណបន្ថែម ថ្វីត្បិតបើវាបានជាប់ការត្រួតពិនិត្យសោតវិញ្ញាណល្អធម្មតា នៅពេលកើតក៏ដោយ ។ វាគឺជាសារៈសំខាន់ ដើម្បីពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់កូនអ្នក ហើយណាត់ពេលជួប សំរាប់ការធ្វើតេស្តសោតវិញ្ញាណជាបន្ថែមទៀត បើសិនជា :

* ជនណាម្នាក់ក្នុងគ្រួសាររបស់អ្នក ថ្លង់ ឬត្រចៀកធ្ងន់ ពីកំណើត ឬបើគេខូចសោតវិញ្ញាណរបស់គេក្នុងកុមារវ័យ
* ម្តាយបានកើតរោគដំបៅក្លាយក្នុងពេលមានផ្ទៃពោះ ដូចជារោគរើម ឬរោគស្វាយ
* ទារករបស់អ្នក មានដំបៅក្លាយធ្ងន់ធ្ងរ ឬមានជំងឺដែលត្រូវការនូវការព្យាបាលក្នុង ផ្នែកថែទាំកូនខ្ចីយ៉ាងហ្មត់ចត (Neonatal Intensive Care Unit – NICU)
* អ្នកបានព្រួយបារម្ភ ថាទារករបស់អ្នកមិនរៀនសូត្រដូចក្មេងៗឯទៀតដែលមានអាយុស្របាលគ្នា
* ទារក ឬកូនតូចរបស់អ្នក មានដំបៅត្រចៀកច្រើន
* ទារក ឬកូនតូចរបស់អ្នក មានដំបៅក្លាយធ្ងន់ធ្ងរដូចជារោគរលាកស្រោមខួរក្បាល
* ទារក ឬកូនតូចរបស់អ្នក បានរបួសក្បាលរបស់វា
* ទារក ឬកូនតូចរបស់អ្នក មានអាការរោគដែលអាចនឹងបណ្តាលឲ្យខូចសោតវិញ្ញាណ

Universal Newborn Hearing Screening Program (កម្មវិធីជាសាកល ត្រួតពិនិត្យសោតវិញ្ញាណកូនទើបកើត)

* ការជ្រោមជ្រែងគ្រួសារ
* ការផ្សព្វផ្សាយ និងការអប់រំ
* ការជ្រោមជ្រែងគ្នារវាងមាតាបិតា-និង-មាតាបិតា
* ព័ត៌មាន និងការបញ្ជូនសំណុំរឿងពេទ្យ
* ការផ្តល់ជំនួយបច្ចេកទេសសំរាប់គ្រួសារ ពីមន្ទីរពេទ្យសំរាលកូន និងមណ្ឌលធ្វើតេស្តសោតវិញ្ញាណ
* ព័ត៌មានសំរាប់គ្រួសារ ពីអ្នកវិជ្ជាជីវៈពេទ្យ និង Early Intervention (ការអន្តរាគមន៍ពីដើមដំបូង)
* ការតភ្ជាប់ទៅនឹងបណ្តាញកិច្ចការបំរើដែលមានផ្តល់ជូន

Universal Newborn Hearing Screening Program (កម្មវិធីជាសាកល ត្រួតពិនិត្យសោតវិញ្ញាណកូន ទើបកើត) ជួយគ្រួសារឲ្យទទួលការបំរើដែលគេត្រូវការ ។ សូមទូរស័ព្ទមកយើងនៅថ្ងៃនេះ បើសិនជាអ្នកមានសំណួរ ឬចង់ដឹងពីទីកន្លែងធ្វើតេស្តសោតវិញ្ញាណ ។

Universal Newborn Hearing Screening Program

ព័ត៌មានសំរាប់គ្រួសារ សូមទូរស័ព្ទ ឬផ្ញើអ៊ី-មៀលមកយើង
សំឡេង 800-882-1435 (មានសំឡេងស្តាប់)
TTY 617-624-5992 (សំរាប់មនុស្សថ្លង់)
ផ្ញើអ៊ី-មៀល : newborn.hearing@state.ma.us

ឃោសនាប័ណ្ណនេះ បានទទួលការឧបត្ថម្ភដោយផ្នែកខ្លះតាមរយៈ Department of Health and Human Services Health Resources and Services Administration, Maternal and Child Health Bureau (ក្រសួងសុខាភិបាល និងបណ្តាញកិច្ចការសុខភាពមនុស្ស និងនាយកដ្ឋានផ្តល់កិច្ចការ, ការិយាល័យសុខភាពម្តាយ និងកុមារ), CFDA លេខ 93.251 សម្បទានលេខ 5 H61 MC 00002-03

Khmer




# តើទារករបស់អ្នក អាចស្តាប់ឮ កំណាព្យបំពេរនេះ ឬទេ?

Universal Newborn Hearing Screening Program

Massachusetts Department of Public Health